**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស**
**នាយកដ្ឋានកិច្ចការអាស៊ាន**

លេខ:.................................

# សេចក្តីជូនព័ត៌មាន

តបតាមការអញ្ជើញរបស់ ឯកឧត្តម Pehin Datu Lailaraja Major General (Retired) Dato Paduka Seri Haji Awang Halbi Bin Haji MD Yussof រដ្ឋមន្ត្រីការពារជាតិប្រ៊ុយណេដារ៉ូសាឡាម **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំប្រតិភូយោធាជាន់ខ្ពស់ក្រសួងការពារជាតិ ចូលរួមកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការពារជាតិអាស៊ាន (ADMM Retreat) កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-សាធារណរដ្ឋកូរ៉េ និងកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-អូស្ត្រាលី នាថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ តាមប្រព័ន្ធonline។

១.នៅក្នុងកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការពារជាតិអាស៊ាន **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងចូលរួមចែករំលែកទស្សនៈ ស្តីពីអនាគតនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន។

២. នៅក្នុងកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-សាធារណរដ្ឋកូរ៉េ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងចូលរួមពិនិត្យឡើងវិញនូវកិច្ចសហប្រតិបត្តិការពហុភាគី ក្នុងការយកឈ្នះលើការគំរាមកំហែងផ្នែកសន្តិសុខដែលមិនមែនប្រពៃណីដូចជា សន្តិសុខលម្ហសមុទ្រ ការសង្គ្រោះគ្រោះមហន្តរាយ។

៣. ស្របគ្នានឹងកិច្ចប្រជុំនេះដែរ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងចូលរួមកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-អូស្ត្រាលី។ ក្នុងកិច្ចប្រជុំនេះ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹង៖ ១) ចូលរួមពិនិត្យលើបច្ចុប្បន្នភាពសកម្មភាពពង្រឹងការចូលរួមរបស់អូស្ត្រាលីជាមួយអាស៊ាន ២) ការរៀបចំសកម្មភាពរបស់អូស្ត្រាលីជាមួយអាទិភាពអាស៊ាន និង៣) កំណត់ទិសដៅអនាគតសម្រាប់ភាពជាដៃគូអាស៊ាន-អូស្ត្រាលី។

៤.នៅចុងបញ្ចប់កម្មវិធី **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងចូលរួមពិធីប្រគល់-ទទួល ជាប្រធានADMM 2022 ពីរដ្ឋមន្ត្រីការពារជាតិទី២ ប្រ៊ុយណេដារ៉ូសាឡាម។